


ដោយស៊ីស្ទើរ ចយ ឌី ចូនស៍
ប្រធានអង្គការបឋមសិក្សាទូទៅ


# ព្រះវិហារបរិសុទ្ធ និង ប្អូន




រចនារូបភាពដោយ យ៉ារ៉េត ម៉ាថាយ

ពីមុនសាសនាចក្រត្រូវបានស្តារឡើងវិញ មនុស្សបានជឿថា ប្រសិនបើនរណាម្នាក់នៅក្នុងគ្រួសារពួកគេបានទទួលមរណភាពដោយមិនបានទទួលបុណ្យជ្រមុជទឹក នោះពួកគេនឹងមិនដែលបានជួបពួកគេម្តងទៀតទេ ។ ប៉ុន្តែដោយសារតែការស្តារឡើងវិញ យើងអាចធ្វើបុណ្យជ្រមុជទឹកសម្រាប់ពួកគេនៅក្នុងព្រះវិហារបរិសុទ្ធ ។ យើងអាចផ្សារភ្ជាប់ជាមួយគ្នាសម្រាប់ភាពអស់កល្បជានិច្ច !

ដូចយ៉ូសែបស្ម៊ីធដែរ ប្អូនក៏ត្រូវបានជ្រើសរើសដោយព្រះវរបិតាសួគ៌ដើម្បីធ្វើកិច្ចការដ៏សំខាន់នៅក្នុងជីវិតប្អូនដែរ ។ កិច្ចការមួយចំនួនអាចត្រូវបានធ្វើឡើងនៅក្នុងព្រះវិហារបរិសុទ្ធ ។ ប្អូនអាចប្រមូលឈ្មោះបុព្វការីជនរបស់ប្អូន ដែលពុំបានទទួលបុណ្យជ្រមុជទឹកពេលពួកគេនៅរស់លើផែនដី ។ បន្ទាប់មក ពេលប្អូនទទួលបានបណ្ណចូលព្រះវិហារបរិសុទ្ធ នោះប្អូនអាចទៅព្រះវិហារបរិសុទ្ធ ហើយទទួលបុណ្យជ្រមុជទឹកសម្រាប់ពួកគេ ។

ពេលប្អូនធ្វើកិច្ចការនេះ សូមអធិស្ឋានទៅព្រះវរបិតាសួគ៌ដើម្បីដឹកនាំប្អូន ។ បុព្វការីជនរបស់ប្អូនអាចជួយប្អូនផងដែរ ។ នោះជាពរជ័យដ៏សំខាន់ និងពិសិដ្ឋមួយសម្រាប់ប្អូន និងសម្រាប់ពួកគេ !

ពួកប្អូនមួយចំនួនប្រហែលមិនទាន់អាចធ្វើកិច្ចការព្រះវិហារបរិសុទ្ធបានឥឡូវនេះ ប៉ុន្តែប្អូននឹងអាចធ្វើបាននៅថ្ងៃមួយ ។ ចូរចងចាំជានិច្ចថា ប្អូនគឺជាបុត្ររបស់ព្រះ ! ទ្រង់ស្រឡាញ់ប្អូនយ៉ាងឥតខ្ចោះ ។

ចូរស្តាប់ការបំផុសពីព្រះវិញ្ញាណបរិសុទ្ធ ហើយរៀបចំជាស្រេចដើម្បីទៅកាន់ព្រះវិហារបរិសុទ្ធនៅថ្ងៃមួយ ។ ការធ្វើដូច្នេះ នឹងជួយប្អូនឲ្យកសាងជីវិតដ៏ប្រពៃមួយសម្រាប់ខ្លួនប្អូន និងសម្រាប់គ្រួសារពីអតីតកាល បច្ចុប្បន្ន និងអនាគតរបស់ប្អូន ។ កាលដែលប្អូនធ្វើកិច្ចការរបស់ព្រះអម្ចាស់ ទ្រង់នឹងជួយប្អូន ។ ប្អូនគឺជាវិញ្ញាណដ៏ក្លៀវក្លាបំផុតមួយរបស់ទ្រង់ ។ ●